អិនថ្រាក្ស (Anthrax)

អ្វីទៅដែលហៅថាអិនថ្រាក្ស?

អិនថ្រាក្ស បានយកមកប្រើនៅក្នុងការវាយប្រហារដោយអំពើភេរវកម្ម។ វាជារោគវ៉ីសាហាវ។ វាពុំមែនជារោគឆ្លងរោគទេ។ អ្នកពុំអាចឈឺដោយឆ្លងពីមនុស្សដែលមានរោគនេះទេ។

តើអ្នកអាចមានជម្ងឺអិនថ្រាក្ស មកពីណាដែរ?

អ្នកអាចកើត ដោយវិធី៣យ៉ាង:

- វាអាចជ្រាបចូលក្នុងសាច់ដោយសារតែមានស្បែកដែលរយះ។
- ដោយសារការដកដង្ហើមដែលជាតិ អិនថ្រាក្ស មាននៅតាមខ្យល់។
- ដោយសារតែពិសារចំណីអាហារដែលមានជាតិ អិនថ្រាក្ស។

តើអិនថ្រាក្សនេះ វាសហាវយ៉ាងណាដែរទៅ?

មនុស្សភាគច្រើនចំនួន (99%) ដែលញ្ជាចាលជាបន្ទាន់លើស្បែកដែលប៉ះជាតិ អិនថ្រាក្ស អាចមានជីវិតរស់រាន។ ប្រសិនបើមិនបានញ្ជាចាលទេ ចំនួន 20% នឹងត្រូវស្លាប់។

ការដកដង្ហើមស្រូបជាតិអិនថ្រាក្ស អាចមានគ្រោះថ្នាក់ខ្លាំងណាស់។ ប្រជាជនចំនួនពាក់កណ្តាលដែលដកដង្ហើមចូលជាតិអិនថ្រាក្ស នឹងត្រូវស្លាប់។

ក្នុងលក្ខណៈកំរជាតិអិនថ្រាក្ស មាននៅក្នុងអាហារពីធម្មជាតិ។ សាច់អាហារដែលមានរោគជាតិអិនថ្រាក្ស ពេលយើងទទួលទានអាចធ្វើឲ្យស្លាប់ក្នុងកំរិត 25% ទៅ 50%។ ជនណាម្នាក់អាចដាក់ជាតិអិនថ្រាក្ស ទៅក្នុងអាហារដើម្បីបំពុលអ្នកដែលទទួលទានអាហារនោះ។

តើវាមានរោគសញ្ញាយ៉ាងណាដែរ?

ស្បែកដែលមានអិនថ្រាក្ស ធ្វើឲ្យមានកន្ទួលរមាស់ (ភាគច្រើននៅតាមមុខ,ប្រអប់ដៃឬដៃ)ហើយវាអាចធ្វើឲ្យ



មានពងបែក។ ពងបែកនេះធ្វើឲ្យមានការឈឺចុកដែលមានចំណុចខ្មៅចំកណ្តាល។

ប្រសិនបើ**ដកដង្ហើមស្រូបចូលជាតិអិនថ្រាក្ស**, អ្នកអាចមានអារម្មណ៍ដូចជាកើតគ្រុនឬគ្រុនក្តៅ,ប៉ុន្តែវាមិនហៀសំចោរនោះទេ។ អ្នកអាចមានឈឺបំពង់ក,ក្តៅខ្លួននិងឈឺចុកសាច់ដុំ,ក្អក,មានដង្ហើមខ្ចី,តឹងទ្រូង,និងអស់កម្លាំង។

សាច់អាហារដែលមានរោគអិនថ្រាក្ស អាចធ្វើឲ្យចង្អោរ, ឈប់ឃ្លាន,រាកឈាម,ក្តៅខ្លួន,នឹងចុកពោះ។

តើរោគសញ្ញាផ្តើមនៅពេលណា?

រោគសញ្ញានៃការប៉ះរោគពុលនៃជាតិអិនថ្រាក្ស ទាំងបីយ៉ាងនេះវានឹងធ្វើឲ្យកើតនូវក្នុងរយៈវេលា៧ថ្ងៃ បន្ទាប់ពីបានប៉ះជាតិអិនថ្រាក្ស។

ប្រសិនបើអ្នកដកដង្ហើមស្រូបចូលជាតិអិនថ្រាក្ស, រោគសញ្ញាអាចកើតក្នុងកំឡុងពេលមួយអាទិត្យឬក៏ក្នុងកំឡុងមួយខែក៏ សឹងមាន។

តើជាតិអិនថ្រាក្ស វាមានសណ្ឋានដូចម្តេចដែរ?

ភាគច្រើនតាំងដើមមកគេឃើញជាតិនេះជាម្សៅពណ៌ស។ ប្រសិនបើអ្នកមិនស្គាល់ហើយឃើញម្សៅពណ៌សនៅក្នុងសំបុត្ររបស់អ្នក

ឬនៅតាមកន្លែងណាផ្សេង,សូមអនុវត្តន៍ដូចតទៅនេះ:

- កុំប៉ះពាល់ឬហិតខ្ចិនវាឲ្យសោះ ។
- ច្រាប់អ្នកដទៃកុំឲ្យទៅជិតម្សៅនោះ ឲ្យសោះ។
- លាងដៃរបស់អ្នក។
- ទូរស័ព្ទទៅកាន់ក្រសួងរំលត់ភ្លើងឬប ូ លិស។

ប្រសិនបើខ្ញុំយល់ឃើញថាខ្ញុំត្រូវបានរុកគួនដោយជាតិអិនថ្រាក្ស តើធ្វើយ៉ាងណា?

ទូរស័ព្ទទៅកាន់ត្រូពេទ្យ មន្ទីរពេទ្យភ្លាម គេនឹងជំរាបអំពីរបៀបដែលត្រូវធ្វើ។

តើមានថ្នាំចាក់ការពារដែរឬទេ?

វាមានពិតមែនហើយ,ប៉ុន្តែវាមានសម្រាប់តែអ្នកដែលយាយីដោយជាតិអិនថ្រាក្ស និងសម្រាប់បុគ្គលដែលធ្វើការនៅកន្លែងដែលទទួលរងគ្រោះខ្លាំងដូចជាពួកទាហាន និងអ្នកធ្វើការនៅមន្ទីរសុខាភិបាល។

ពត៌មានបន្ថែម...

ទូរស័ព្ទទៅ CDC: ទទួលជំនួយជាភាសាអង់គ្លេស ឬស្ប៉ានីស:
800-CDC-INFO (800-232-4636)
888-232-6348 (TTY)

ឬចូលទៅបណ្តាញ: www.cdc.gov/anthrax
www.dhs.ca.gov/epo